ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
FAX PHONE (855) 23 27798

លេខ: ២២៤ ប្រក.សហវ.ពដ

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ១៩៩៦

# ប្រកាស
## ស្តីពី
# ការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា,
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា,
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤,
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល,
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល,
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម នស.រកម.០១៩៦.១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦,
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១.នស.៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤,

- បានឃើញច្បាប់កែតម្រូវនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ជស.រកម.០៩៩៩.០១ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៩.
- បានឃើញអនុក្រឹត្យលេខ ៥៨អនក្រ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់.
- បានឃើញប្រកាសលេខ ៣១៦ប្រក.សហវ.ពជ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៩ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់.
- បានឃើញសេចក្តីសំរេចលេខ ០១ បសរ.ពជ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់តាមបណ្តាខេត្ត-ក្រុង.
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើដីមិនបានប្រើប្រាស់ ។

## សំរេច:

ប្រការ ១ :

ត្រូវជាប់ពន្ធលើដីមិនបានប្រើប្រាស់ គឺដីទាំងឡាយណាដែលពុំមានលក្ខណៈណាមួយនៃលក្ខណៈ ខាងក្រោមនេះ ៖

១- ដីមានសំណង់ស្ថិតនៅក្នុងតំបន់លំនៅដ្ឋាន ដែលកម្មសិទ្ធិករប្រើប្រាស់ជាកន្លែងស្នាក់នៅជាសំខាន់របស់ខ្លួន និងបានស្នាក់នៅកន្លែងនោះ ចំនួន១៨៣ថ្ងៃ ឬ ច្រើនជាងគិតចាប់ពីថ្ងៃទី០១ តុលា នៃឆ្នាំកន្លងទៅរហូតដល់ថ្ងៃទី៣០ ខែកញ្ញា នៃឆ្នាំប្រមូលពន្ធ ។ បើសិនជានៅក្នុងឆ្នាំប្រមូលពន្ធ កម្មសិទ្ធិករអាចបំពេញល័ក្ខខ័ណ្ឌស្នាក់នៅចំនួន ១៨៣ថ្ងៃ បានសំរាប់ឆ្នាំប្រមូលពន្ធនោះ កម្មសិទ្ធិករអាចដាក់ពាក្យសុំឱ្យបង្វិលសងប្រាក់ពន្ធដែលបានបង់រួចហើយនោះវិញបាន ។

កន្លែងស្នាក់នៅជាសំខាន់របស់កម្មសិទ្ធិករ គឺជាកន្លែងដែលកម្មសិទ្ធិករបានដេកនៅហូបចុកយ៉ាងជាក់លាក់ជារៀងរាល់ថ្ងៃ ក្រោយពីពេលត្រឡប់ពីបំពេញការងារប្រចាំថ្ងៃ ។ សំរាប់ការកំណត់ពន្ធនេះ កម្មសិទ្ធិករម្នាក់ពុំអាចមានទីកន្លែងស្នាក់នៅជាសំខាន់លើសពីមួយកន្លែងបានទេ ។

២- ដីដួលដែលមានសំណង់មានការកាន់កាប់ ដែលផ្តល់លាភការប្រចាំខែលើសពី ៨០៖ នៃចំនួនមួយភាគដប់ពីរនៃតម្លៃដីនៅក្នុងឆ្នាំប្រមូលពន្ធ គុណនឹងមេគុណដែលកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ហើយក្នុងនោះតម្លៃដីត្រូវបានកំណត់ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ ។

៣- ដីដែលមានសកម្មភាពសេដ្ឋកិច្ចស្របតាមការកំណត់តំបន់របស់រដ្ឋ ហើយដែលបានប្រាក់ចំណូលប្រចាំខែអំពីសកម្មភាពនោះ បានលើសពីចំនួន៨០៖ នៃចំនួនមួយភាគដប់ពីរ

នៃតម្លៃដីនៅក្នុងឆ្នាំប្រមូលពន្ធ គុណនឹងមេគុណ ដែលកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ហើយក្នុងនោះតម្លៃដីត្រូវបានកំណត់ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ ។

៤- ដីជាកម្មសិទ្ធិរបស់រដ្ឋ ដែលបានជួលទៅឱ្យនីតិបុគ្គល ឬ រូបវន្តបុគ្គលណាមួយ ហើយដីនោះមានលក្ខណៈណាមួយនៃចំណុចទាំង៣ ខាងលើ ។

៥- ដីដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងវិនិយោគ ហើយដែលសកម្មភាពមិនទាន់បានចាប់ផ្តើមដោយមានប្រធានសក្តិ ឬ ដោយមូលហេតុការរងគ្រោះដោយប្រការអ្វីមួយដូចជាអសន្តិសុខ ហើយការពន្យារពេលនោះត្រូវបានទទួលការយល់ព្រមពីស្ថាប័នជំនាញមានសមត្ថកិច្ច និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ប្រការ ២ :

ការបង់ពន្ធនេះ មិនមែនជាល័ក្ខខ័ណ្ឌបញ្ជាក់កម្មសិទ្ធិស្របច្បាប់លើដីទេ ។

ប្រការ ៣ :

ក្នុងការគ្រប់គ្រងប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ ពាក្យ "កម្មសិទ្ធិករ" សំដៅដល់បុគ្គលណាដែលផ្នែកសុរិយោដី ឬ អាជ្ញាធរដែនដី ចាប់ពីថ្នាក់ឃុំ-សង្កាត់ឡើងទៅ បានចេញឯកសារផ្លូវការទទួលស្គាល់សិទ្ធិរបស់បុគ្គលនោះ ក្នុងការប្រើប្រាស់ដីក្នុងតំបន់ណាមួយជាលក្ខណៈជាប់លាប់ក្តី ឬ បណ្តោះអាសន្នក្តី ។

កម្មសិទ្ធិករម្នាក់ គឺជាក្រុមគ្រួសារមួយ "ឪពុក ម្តាយ សាមីខ្លួន ប្រពន្ធ កូនក្នុងបន្ទុក" ឬ មេគ្រួសារ និងសមាជិកក្នុងបន្ទុកមានឈ្មោះក្នុងប័ណ្ណគ្រួសារ ដែលចេញដោយស្ថាប័នមានសមត្ថកិច្ច ។

កម្មសិទ្ធិករនៃដីជាប់ពន្ធនិងអ្នកជួលដីពីរដ្ឋ ដូចក្នុងចំណុច៤នៃប្រការ១ មានកាតព្វកិច្ចត្រូវគណនាប្រាក់ពន្ធទៅតាមទំរង់ប្រកាសសារពើពន្ធដែលនាយកដ្ឋានពន្ធដារបានផ្តល់ឱ្យ ហើយត្រូវបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ យ៉ាងយឺតបំផុតត្រឹមថ្ងៃ៣០ កក្កដា នៃឆ្នាំប្រមូលពន្ធនិមួយៗ ជូនដល់ផ្នែកពន្ធដារនៅតំបន់ ដែលដីនោះស្ថិតនៅ ។ សំរាប់ដីជាប់ពន្ធនិមួយៗ ត្រូវធ្វើប្រកាសសារពើពន្ធមួយដាច់ដោយឡែក ។

ប្រការ ៤ :

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងប្រកាសជូនដំណឹងជាសាធារណៈអំពីតំលៃដីក្នុងមួយម៉ែត្រក្រឡា ដែលកំណត់ដោយគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ដើម្បីអោយអ្នកជាប់ពន្ធអាចកំណត់មូលដ្ឋានសំរាប់គិតពន្ធរបស់ខ្លួន ។ ការជូនដំណឹងជាសាធារណៈនេះ

ក៏ត្រូវមានចុះបញ្ជាក់ផងដែរ អំពីការបែងចែកជាតំបន់ ហើយនិងការវាយតម្លៃដីក្នុងមួយម៉ែត្រក្រឡាសំរាប់តំបន់នីមួយៗ ។ ការជូនដំណឹងជាសាធារណៈនេះ ត្រូវបិទផ្សាយនៅតាមសាលាខេត្ត-ក្រុង សាខាពន្ធដារ និងការិយាល័យប្រៃសណីយ៍ ហើយត្រូវចុះផ្សាយក្នុងសារពត៌មានចេញផ្សាយ ក្នុងស្រុកចំនួន ២ យ៉ាងតិច ។

ប្រការ ៥ :

ការមិនបានធ្វើប្រកាសសារពើពន្ធ ការបង់ពន្ធមិនគ្រប់ ឬ ការមិនបានបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ត្រូវទទួលរងការដាក់អនុវត្តនូវមាត្រា ៥៨ ហើយនិងមាត្រាមានជាប់ទាក់ទងផ្សេងទៀត នៃច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ១៩៩៤ និង ទោសទណ្ឌដែលមានចែងក្នុងច្បាប់ហិរញ្ញវត្ថុជាធរមាន ។

ប្រការ ៦ :

ប្រកាសនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

*ចំលងជូនៈ*

អគ្គលេខាធិការដ្ឋានរដ្ឋសភា

ទីស្តីការគណៈរដ្ឋមន្ត្រី

ខុទ្ទកាល័យសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១

ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២

គ្រប់ក្រសួង-ស្ថាប័នកណ្តាល

គ្រប់សាលាខេត្ត-ក្រុង

"ដើម្បីជ្រាបជាពត៌មាន"

គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

"ដើម្បីមុខការ"

គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

~~អនុគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់~~

គ្រប់អង្គភាពពន្ធដារ "ដើម្បីអនុវត្ត"

ឯកសារ-កាលប្បវត្តិ